# ការត្រាស់ហៅជាថ្មីហើយខ្ពស់ជាង A NEW AND HIGHER CALLING

## លូកា Luke 5:1-11

១ កាលទ្រង់កំពុងឈរ នៅមាត់សមុទ្រគេនេសារ៉ែត នោះមានមនុស្សកក
កុញប្រជ្រៀតគ្នាមកឯទ្រង់ ដើម្បីនឹងស្តាប់ព្រះបន្ទូល ២ ហើយទ្រង់ទតឃើញ
ទូក២ចតនៅមាត់សមុទ្រ ដែលពួកអ្នកនេសាទបានឡើងទៅលាងអួនហើយ
៣ ទ្រង់យាងចុះទូក១នោះ ជាទូករបស់ស៊ីម៉ូន ក៏សូមឲ្យគាត់ចេញទូកពីនិប
ន្តិចទៅ រួចទ្រង់គង់បង្រៀនដល់បណ្តាមនុស្សពីក្នុងទូកវិញ ៤ លុះឈប់
អធិប្បាយហើយ នោះទ្រង់មានព្រះបន្ទូលទៅស៊ីម៉ូនថា ឲ្យចេញទូកទៅឯ
កន្លែងទឹកជ្រៅទំលាក់អួនចាប់ត្រីចុះ ៥ ស៊ីម៉ូនទូលឆ្លើយថា លោកគ្រូអើយ
យប់មិញ យើងខ្ញុំបានខំនឹកអួនទាល់ភ្លឺ គ្មានបានអ្វីសោះ តែខ្ញុំនឹងទំលាក់អួន
តាមពាក្យលោកមើល ៦ កាលទំលាក់ទៅ នោះក៏ជាប់បានត្រីសន្ធឹក ដល់ម្លេះ
បានជាអួនចាប់តាំងធ្លាយ ៧ នោះគេបោយដៃហៅគូកន ដែលនៅក្នុងទូក១
ទៀត ឲ្យមកជួយគ្នា គេក៏មក ហើយចាប់ដាក់បានពេញទូកទាំង២ ទាល់តែ
ព្រៀបស្ទើរនឹងលិច ៨ កាលស៊ីម៉ូន-ពេត្រុសបានឃើញដូច្នោះ នោះគាត់ក្រាប
នៅទៀបព្រះជង្ឃព្រះយេស៊ូវ ទូលថា ព្រះអម្ចាស់អើយ សូមថយចេញពីទូល
បង្គំ ដ្បិតទូលបង្គំជាមនុស្សមានបាប ៩ គាត់ទូលដូច្នោះ ដោយហេតុគាត់ និង
ពួកអ្នកនៅជាមួយ នឹកស្ញើចក្នុងចិត្ត ពីត្រីដែលបានច្រើនដល់ម្លេះ

១០ ហើយយ៉ាកុប និងយ៉ូហាន ជាកូនសេបេដេ ដែលជាពួកហ៊ុននឹងស៊ីម៉ូន ក៏
ដូច្នោះដែរ តែព្រះយេស៊ូវមានព្រះបន្ទូលទៅស៊ីម៉ូនថា កុំខ្លាចអី ពីនេះទៅមុខ
អ្នកនឹងចាប់មនុស្សវិញ ១១ រួចកាលទូកបានដល់គោក នោះគេទុករបស់
ទាំងអស់ចោល ហើយដើរតាមទ្រង់ទៅ។

## ការត្រាស់ហៅទាមទារអោយមានការប្តេជ្ញាចិត្តខ្ពស់ជាងគេ

THE NEW CALL DEMANDED GREATER COMMITMENT ៥ 4-7

៤ លុះឈប់អធិប្បាយហើយ នោះទ្រង់មានព្រះបន្ទូលទៅស៊ីម៉ូនថា ឲ្យចេញទូកទៅឯកន្លែងទឹក
ជ្រៅទំលាក់អួនចាប់ត្រីចុះ ៥ ស៊ីម៉ូនទូលឆ្លើយថា លោកគ្រូអើយ យប់មិញ យើងខ្ញុំបានខំដឹក
អួនទាល់ភ្លឺ គ្មានបានអ្វីសោះ តែខ្ញុំនឹងទំលាក់អួន តាមពាក្យលោកមើល ៦ កាលទំលាក់ទៅ
នោះក៏ជាប់បានត្រីសន្ធឹក ដល់ម៉្លេះបានជាអួនចាប់តាំងធ្លាយ ៧ នោះគេបោយដៃហៅគូកន
ដែលនៅក្នុងទូក១ទៀត ឲ្យមកជួយគ្នា គេក៏មក ហើយចាប់ដាក់បានពេញទូកទាំង២ ទាល់តែ
ពៀបស្ទើរនឹងលិច។

## ការត្រាស់ហៅជាការអញ្ជើញចូលរួមក្នុងភាពស្និទ្ធស្នាលជ្រៅជាងគេ

THE NEW CALL WAS AN INVITATION TO GREATER INTIMACY ៥ 8

៨ កាលស៊ីម៉ូន-ពេត្រុសបានឃើញដូច្នោះ នោះគាត់ក្រាបនៅទៀបព្រះជង្ឃព្រះយេស៊ូវ ទូល
ថា ព្រះអម្ចាស់អើយ សូមថយចេញពីទូលបង្គំ ដ្បិតទូលបង្គំជាមនុស្សមានបាប។

## ការត្រាស់ហៅជាការហៅមកអោយរស់នៅតាមផ្លូវថ្មីនៃជីវិត

THE NEW CALL IS A CALL TO A NEW- WAY OF LIFE. ៥ 9-11

៩ គាត់ទូលដូច្នោះ ដោយហេតុគាត់ និងពួកអ្នកនៅជាមួយ នឹកស្ញើចក្នុងចិត្ត ពីត្រីដែលបាន
ច្រើនដល់ម៉្លេះ ១០ ហើយយ៉ាកុប និងយ៉ូហាន ជាកូនសេបេដេ ដែលជាពួកហ៊ុននឹងស៊ីម៉ូន ក៏
ដូច្នោះដែរ តែព្រះយេស៊ូវមានព្រះបន្ទូលទៅស៊ីម៉ូនថា កុំខ្លាចអី ពីនេះទៅមុខ អ្នកនឹងចាប់
មនុស្សវិញ ១១ រួចកាលទូកបានដល់គោក នោះគេទុករបស់ទាំងអស់ចោល ហើយដើរតាម
ទ្រង់ទៅ។